**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
## រវាង
## ក្រុមហ៊ុន និសស៊ី ខេមបូឌា ខូ., អិលធីឌី
## និង
## តំណាងប្រតិភូបុគ្គលិក ប្រចាំ
## ក្រុមហ៊ុន និសស៊ី ខេមបូឌា ខូ., អិលធីឌី
## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០២៥ វេលាម៉ោង ១៤ និង ០០នាទី នៅក្នុងក្រុមហ៊ុន **និសស៊ី ខេមបូឌា ខូ., អិលធីឌី** មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត ប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះនាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ន នៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្ញុំមានការកម្មង់ទិញទំនិញមានការធ្លាក់ចុះ ហេតុដូចនេះ ក្រុមហ៊ុន សម្រេចធ្វើការព្យួរកិច្ចសន្យាការងារ របស់កម្មករ និយោជិតចំនួន **១០០ នាក់ (ស្រី ..៨០.. នាក់)** ក្នុងចំណោម កម្មករ **សរុប ៥៨៦ នាក់ (ស្រី ៤៩៦ នាក់)** រយៈពេលចំនួន៣០ថ្ងៃ គឺចាប់ពីថ្ងៃទី០១ ខែ មេសា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២៥ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករ និយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុន នូវប្រាក់ឧបត្ថម្ភចំនួន ៥៥ដុល្លា ក្នុងរយៈពេល ៣០ថ្ងៃ សម្រាប់កម្មករ និយោជិតម្នាក់ៗ ដោយបើកជូននៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២៥ ការព្យួរកិច្ចសន្យាការងារនេះគឺមិនរាប់បញ្ចូល ស្ត្រីមានផ្ទៃពោះ ស្ត្រីសំរាកលំហែមាតុភាព និងកម្មករពិការឡើយ។

អង្គប្រជុំបានបញ្ចប់វេលាម៉ោង១៤ និង ៤០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ស្វាយរៀង, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២៥

**តំណាងកម្មករ** | **នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន និសស៊ី (ខេមបូឌា) NISSEY (CAMBODIA) CO., LTD. KINGDOM OF CAMBODIA

Hoshino